ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំ
អង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករ
សេដ្ឋកិច្ចក្រៅប្រព័ន្ធ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន អំពីលទ្ធផលការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ដូចខាងក្រោម៖

## ក-ការចាក់វ៉ាក់សាំងដូសទី១

➢ **លទ្ធផលក្នុងថ្ងៃទី២៨ ខែមេសា**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ៦ ៦៥៩នាក់ (បរទេសចំនួន ០នាក់)
- ចាក់បានចំនួន ៦ ៥៩៩នាក់ (បរទេសចំនួន ០នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៦០នាក់ (បរទេសចំនួន ០នាក់)

➢ **លទ្ធផលគិតត្រឹមថ្ងៃនេះ**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ១១៣ ៣២៩នាក់ (បរទេសចំនួន ៣ ៧៦៩នាក់)
- ចាក់បានចំនួន ១១០ ១៨៧នាក់ (បរទេសចំនួន ៣ ៧៤៨នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៣ ១៤២នាក់ (បរទេសចំនួន ២១នាក់)

## ខ-ការចាក់វ៉ាក់សាំងដូសទី២

➢ **លទ្ធផលក្នុងថ្ងៃទី២៨ ខែមេសា**

- ចាក់បានចំនួន ៥ ២៦៦នាក់ (បរទេសចំនួន ១០៨នាក់)

➢ **លទ្ធផលគិតត្រឹមថ្ងៃនេះ**

- ចាក់បានចំនួន ១៥ ១៧៧នាក់ (បរទេសចំនួន ៥៨៣នាក់)

អនុគណៈកម្មការចំពោះកិច្ច នឹងបន្តរៀបចំទីតាំងចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ជាបន្តបន្ទាប់ទៀត។

អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១